00720683

**Declassified to Public**
**28 October 2021**

D22

នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Jun-2011, 08:31
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត: សម្ងាត់/Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ០០៣ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្ខេបលើស្ថានភាពនៃកិច្ចស៊ើបសួរ**

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញាអន្តរជាតិ:
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
ការិ.សហចៅក្រមស៊ើបអង្កេត:
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Siegfried BLUNK

**ចម្លងជូន:**
សហព្រះរាជអាជ្ញាជាតិ:
លោកស្រី ជា លាង

# ពាក្យសុំឲ្យទទួលស្គាល់ចំពោះសុពលភាពនៃសំណើ សុំឲ្យបំពេញកិច្ចស៊ើបសួរ

១. កាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសំរេចរបស់ខ្លួនលើសំណើសុំពន្យាពេលបន្ថែម និងសុំឲ្យបំពេញកិច្ចស៊ើបសួរដែលធ្វើឡើងដោយសព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿងលេខ០០៣ ("ដីកាសម្រេច")[1] ដែលតាមដីកាសំរេចនេះ សហចៅក្រមស៊ើបអង្កេតបានបដិសេធនូវសំណើសុំចំនួនបួនដែលបានដាក់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង ថាគ្មានសុពលភាព៖ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរចំនួនបីដែលរួមមាន សំណើសុំក្នុងពេលនេះ[2] និងសំណើមួយដែលសុំឲ្យពន្យារពេលកំណត់សំរាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០៣[3] ។ អនុលោមតាមវិធាន៣៩.៤ នៃវិធានផ្ទៃក្នុង និងមាត្រា ៨ និង៩ នៃសេចក្តីណែនាំអនុវត្តក្នុងការដាក់ឯកសារនៅចំពោះមុខ អវតក សហព្រះរាជអាជ្ញាអន្តរជាតិ សូមដាក់ជូនសារជាថ្មីឡើងវិញនូវសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ និងសូមស្នើឲ្យសហចៅក្រមស៊ើបអង្កេតទទួលស្គាល់នូវសុពលភាពនៃសំណើសុំនេះ ថាជាបណ្តឹងដែលកំពុងតែអនុវត្តនៅបន្ទាប់ពីការផុតនៃពេលវេលាកំណត់ ដោយផ្អែកតាមការដែលខ្លួនយល់ឃើញថាជាការសមស្រប។

២. មូលដ្ឋាននៃការការដាក់សំណើនេះសារជាថ្មី នៅក្រោយពេលហួសកំណត់ដែលបានចែងនៅក្នុងវិធាន៦៦.១ នៃវិធានផ្ទៃក្នុង គឺថា សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចស្តីពីការបកស្រាយរបស់ខ្លួនពាក់ព័ន្ធទៅនឹងទម្រង់បែបបទ ដែលចាំបាច់សម្រាប់ឲ្យសហព្រះរាជអាជ្ញាណាមួយដាក់សំណើសុំបែបដូច្នេះ តែម្នាក់ឯង ។ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនេះត្រូវបានច្រានចោលដោយមានមូលដ្ឋាននៅលើបច្ចេកទេសនៃនីតិវិធីចំនួនពីរ និងមិនត្រូវបានពិចារណាលើអង្គសេចក្តីរបស់វាឡើយ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ដើម្បីឲ្យសហព្រះរាជអាជ្ញា

[1] ដីកាសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៣ របស់ កសចស, D20/3, ថ្ងៃទី៧ មិថុនា ២០១១ ("ដីកាសម្រេច") ។

[2] សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទី១ របស់ហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ, ថ្ងៃទី១៨ ឧសភា ២០១១, D17 ។ សំណើលើកទី២ របស់ហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស, ថ្ងៃទី១៨ ឧសភា ២០១១, D18 ។ សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ, ថ្ងៃទី១៨ ឧសភា ២០១១, D19 ។

[3] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលវេលាកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០៣ និងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដាក់ដោយ ទាក់ទងនឹងសំណុំរឿងលេខ០០៣, ថ្ងៃទី១០ ឧសភា ២០១១, D15 ។

ណាមួយម្នាក់ចាត់វិធានការតែម្នាក់ឯង គឺវាត្រូវតែមានការផ្ទេរនូវសិទ្ធិអំណាចតាមផ្លូវការ ទៅតាមវិធាន១៣.៣ ឬ ការខ្វែងយោបល់ត្រូវបានចុះបញ្ជី ដោយអនុលោមវិធាន៧១.១ នៃវិធានផ្ទៃក្នុង[4] ។ ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិកំពុងប្តឹងឧទ្ធរណ៍ ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត លើវិធានផ្ទៃក្នុងទាក់ទងទៅនឹងការចុះបញ្ជីលើការខ្វែងយោបល់គ្នា សហព្រះរាជអាជ្ញាឥឡូវនេះ បានធ្វើការកត់ត្រានូវចរិតលក្ខណៈចំៗនៃការខ្វែងយោបល់របស់ពួកខ្លួន ដែលទាក់ទងទៅនឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ នៅលើឯកសារមួយដែលបានចុះហត្ថលេខា និងចុះកាលបរិច្ឆេទនៅថ្ងៃនេះ ហើយបានដាក់វាចូលទៅក្នុងបញ្ជីខ្វែងយោបល់គ្នាមួយ ដែលត្រូវបានរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញា ។

៣. ដោយសារសំណុំបែបបទមួយក្នុងចំណោមសំណុំបែបបទនានា ដែលចាត់ទុកថាចាំបាច់ត្រូវធ្វើតាមរយៈសេចក្តីសំរេចឥឡូវនេះត្រូវបានបំពេញសព្វគ្រប់ ហើយមិនមានធ្វើឱ្យខូចដល់បណ្តឹងឧទ្ធរណ៍ដែលត្រូវដាក់ដោយ សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងបញ្ហានេះ សហព្រះរាជអាជ្ញា សូមស្នើដល់សហចៅក្រមស៊ើបអង្កេតមេត្តាទទួលស្គាល់ថា សំណើសុំឱ្យបំពេញកិច្ចស៊ើសួរនេះមានសុពលភាព ហើយឥឡូវនេះសូមឱ្យមេត្តាធ្វើការពិនិត្យលើអង្គសេចក្តី។ ការអនុវត្តនូវឆន្ទានុសិទ្ធិតាមរបៀបនេះនឹងធានាឱ្យប្រាកដថា បច្ចេកទេសក្នុងការគ្រប់គ្រងផ្នែកច្បាប់ គឺមិនជាឧបសគ្គរាំងដល់ភាពត្រឹមត្រូវ ភាពប្រាកដប្រជានៃច្បាប់ និងតម្លាភាពនៃដំណើរការនីតិវិធីអនុលោមតាមវិធាន២១.១ នៃវិធានផ្ទៃក្នុង ហើយនឹងសិទ្ធិជាមូលដ្ឋានរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការធ្វើសំណើសុំឱ្យបំពេញកិច្ច ស៊ើបសួរជាបន្ថែមទៀត នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចស៊ើបសួរ អនុលោមតាមវិធាន៦៦.១ នៃវិធានផ្ទៃក្នុង។

## សេចក្តីផ្តើម

៤. អនុលោមតាមវិធាន៦៦(១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាអន្តរជាតិសូមដាក់ជូនសហចៅក្រម (ស.ច.ស) នូវសំណើបំពេញកិច្ចស៊ើបសួរខាងក្រោមនេះដើម្បីទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ (“សំណើ”)[5] ទាក់ទងនឹងជនសង្ស័យនិងទីតាំងឧក្រិដ្ឋកម្មនានា

---

[4] ដីកាសម្រេច, កថាខណ្ឌទី ៥ ។

[5] សំណើនេះត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងប៉ុណ្ណោះ ។ ទម្លាប់នៃការអនុវត្តដូច្នេះត្រូវបានទទួលយកថាជាការត្រឹមត្រូវ: ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ត្រូវបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិស្របតាមសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ (D1/1/1); លិខិតចាត់ឱ្យស៊ើបសួរជំនួស (D2) ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេត

ដូចបានចង្អុលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ដែលបានដាក់ជូន នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩[6] ។

៥. សំណើនេះត្រូវបានដាក់អមទៅជាមួយនឹងសំណើសុំបំពេញកិច្ចស៊ើបសួរពីរបន្ថែម (សំណើបន្ថែម) ដែលសំណើនីមួយៗគូសបញ្ជាក់ពីកិច្ចស៊ើបសួរជាក់លាក់ដែលត្រូវបំពេញ ទាក់ទងនឹងជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យនានា និងទីតាំងឧក្រិដ្ឋកម្ម/ព្រឹត្តិការណ៍ព្រហ្មទណ្ឌផ្សេងៗ ។ សំណើនេះក៏មានផ្ទុកនូវសេចក្តីសង្កេតធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិផងដែរ ទៅលើស្ថានភាពនៃកិច្ចស៊ើបសួរជារួម ហើយដែលមិនបានលើកយកមកនិយាយឡើងវិញទេនៅក្នុងសំណើសុំបន្ថែម ដើម្បីរក្សាសវ្សភាព ។

## ស្ថានភាពនៃកិច្ចស៊ើបសួរ

៦. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា កិច្ចស៊ើបសួរដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត មកទល់ពេលនេះ ត្រូវបានពិចារណាថា មិនទាន់បញ្ចប់ទេ ដោយសារកត្តាមួយចំនួនដូចជា: កិច្ចស៊ើបសួរដល់ទីកន្លែងធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) មានលក្ខណៈរិតត្បិតហួសហេតុ ដែលនាំឲ្យបណ្តាញនៃកិច្ចស៊ើបសួរជាច្រើនទៀត នៅតែមិនទាន់បានស្រាវជ្រាវនៅឡើយ; ភាពយឺតយ៉ាវនៃការដាក់ឯកសារទៅក្នុងសំណុំរឿង ដែលជាហេតុធ្វើឲ្យសហព្រះរាជអាជ្ញា មិនអាចចូលរួមឲ្យបានប្រសិទ្ធិភាពនៅក្នុងកិច្ចស៊ើបសួរ និងដោយសារការពិតដែលថា ជនសង្ស័យមិនត្រូវបានគេជូនដំណឹងថា ពួកគេកំពុងស្ថិតក្រោមកិច្ចស៊ើបសួរដែលពួកគេត្រូវបានភ្ជាប់ដោយភស្តុតាងឯកសារ និងសក្ខីកម្មនានា ។

៧. សហព្រះរាជអាជ្ញាអន្តរជាតិសូមរលើកឡើងវិញថា ប្រព័ន្ធច្បាប់ស៊ីវិល ដូចបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង ជាតាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើការស៊ើបសួរទៅលើអង្គហេតុនានា ដូចបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ តាមរយៈបទសម្ភាសន៍តែពីរបីដែលបានធ្វើឡើង តាំងពីពេលផុតកំណត់នៃដីកាចាត់ឲ្យស៊ើបសួរជំនួសលើកទីមួយតែមួយគត់ដែលបានចេញក្នុងករណីនេះ គឺហាក់ដូចជា ស.ច.ស បាន: (i) កំរិតទៅលើតែការស្រាវជ្រាវដ៏រិតត្បិតរបស់ខ្លួន ចំពោះតែមុខតំណែងដែលបានកាន់កាប់ដោយជនសង្ស័យ

អន្តរជាតិ; សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានស្វែងរកការបញ្ជាក់បំភ្លឺទាក់ទិននឹងវិសាលភាពនៃកិច្ចស៊ើបសួរ ពីសហព្រះរាជអាជ្ញាអន្តរជាតិ (D1/2) ហើយបានទទួលការដាក់ចម្លើយតបពីសហព្រះរាជអាជ្ញាអន្តរជាតិ (D1/2/1) ។

[6] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ, ៧ កញ្ញា ២០០៩, D1/1 ។

តែពីរនាក់គត់[7] និង (ii) អាស្រ័យហេតុនេះបានជាបញ្ឈប់កិច្ចស៊ើបសួរស៊ីជម្រៅទៅលើការអះអាងចោទប្រកាន់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម (រួមទាំងប្រភេទនៃបទឧក្រិដ្ឋ និងវិសាលភាពពេលវេលា និងភូមិសាស្ត្ររបស់វា ព្រមទាំងចំនួនជនរងគ្រោះ) ។ ការអះអាងចោទប្រកាន់ទាក់ទងនឹងផែនការឧក្រិដ្ឋកម្មរួម និងសិទ្ធិអំណាចទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ គឺនៅតែមិនទាន់បញ្ចប់សព្វគ្រប់ដូចគ្នាដែរ ។ ទាក់ទងនឹងការចេញសេចក្ដីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរមុនការបញ្ចប់សព្វគ្រប់នៃការស៊ើបសួរដ៏ពេញលេញមួយ សហព្រះរាជអាជ្ញាអន្តរជាតិគ្រាន់តែអាចសន្មតថា ស.ច.ស អាចបានបង្កើតនូវទម្រង់នៃទស្សនៈមួយថាតើ ជនសង្ស័យទាំងពីរនាក់ស្ថិតក្នុងប្រភេទជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងអម្លុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ដែរឬអត់តែប៉ុណ្ណោះ ។

៨. សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថាមិនថា ស.ច.សមានទស្សនៈយល់ឃើញជាបឋមយ៉ាងដូម្ដេចឡើយចំពោះបញ្ហានេះ គឺថា កិច្ចស៊ើបសួរពេញលេញមួយលើការអះអាងចោទប្រកាន់ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ គឺជាកាតព្វកិច្ចខានមិនបាន ។ ការបិទកិច្ចស៊ើបសួរនៅដំណាក់កាលនេះ មានតម្លៃស្មើនឹងការរំលោភលើវិធាន៥៥(២) នៃវិធានផ្ទៃក្នុង ហើយការសម្រេចណាមួយអំពីបញ្ហាយុត្តាធិការគឺច្បាស់ណាស់ថាគឺជាការឆាប់ពេក ។ ដោយសារអវត្តមាននៃកិច្ចស៊ើបសួរដ៏ពេញលេញមួយ ស.ច.ស នឹងមិនបានប្រមូលភស្តុតាងចាំបាច់ទាំងអស់ដើម្បីសម្រេចលើបញ្ហានៃយុត្តាធិការបុគ្គលបានឡើយ ។ ការបញ្ជូនឯកសារសំណុំរឿងលេខ ០០២ និងបទសម្ភាសន៍តែមួយក្ដាប់តូច គឺនៅក្រោមឆ្ងាយណាស់ពីប្រភេទនៃកិច្ចស៊ើបសួរដែលជាលក្ខខណ្ឌតម្រូវសម្រាប់ ស.ច.ស ដើម្បីសម្រេចថាតើ ជនសង្ស័យ គឺជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែរឬក៏អត់នោះ ។

៩. នៅក្នុងសំណុំរឿងលេខ០០២ អង្គបុរេជំនុំជម្រះបានសម្រេចថា ដីកាដំណោះស្រាយតំនាងឲ្យដីកាមួយដែលបញ្ជាក់អំពីយុត្តាធិការរបស់តុលាការ[8] ។ នោះគឺមានន័យថា ទោះបីជាបុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីមួយ អាចនឹងត្រូវបានរកឃើញយ៉ាងច្បាស់ថា មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះនៅពេលដែលចេញដីកាដំណោះស្រាយក៏ដោយក៏ ការណ៍នេះមិនបានធ្វើឲ្យ សចស រួចចាកផុតពីកាតព្វកិច្ចរបស់ខ្លួនក្នុងការបំពេញកិច្ចស៊ើបសួរដ៏ពេញលេញមួយលើការលើកឡើងចោទប្រកាន់អំពីឧក្រិដ្ឋកម្មនានា និងអំពីការទទួលខុសត្រូវជាបុគ្គលរបស់ជនសង្ស័យទាំងនេះឡើយ ។ គឺលុះត្រាតែនៅពេលដែលកិច្ចស៊ើបសួរពេញ

[7] ដីកាចាត់ឲ្យស៊ើបសួរជំនួស, ៩ មិថុនា ២០១០, D2 ។ របាយការណ៍ស្ដីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស, ១០ កុម្ភៈ ២០១១, D2/1 ។ កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈូក រិន, ២៤ មីនា ២០១១, D6; កាំង ហ្កេចអ៊ាវ *ហៅ*ឌុច, ២៧ មេសា ២០១១, D12; សំ ប៊ុនឡេង, ២១ មីនា ២០១១, D8 ។

[8] សំណុំរឿងលេខ ០០២: សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធិ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, D427/3/15, ត្រង់ទំព័រទី៣០-៣៣ ។

លេញត្រូវបានចប់សព្វគ្រប់ហើយប៉ុណ្ណោះទើប សហព្រះរាជអាជ្ញា នឹងធ្វើការវិភាគលើភស្តុតាងដែលប្រមូលបាន (ដែលរួមទាំងភស្តុតាងទាំងឡាយដែលទាក់ទងទៅនឹងតួនាទីរបស់ជនត្រូវចោទទាំងនេះផង) ហើយនឹងធ្វើសេចក្តីសន្និដ្ឋានលំអិតទាក់ទងនឹងការចេញដីកាដំណោះស្រាយ ។

១០. បញ្ហាទាំងឡាយដែលត្រូវធ្វើការស៊ើបសួរឲ្យបានពេញលេញ នៅមុនពេល សចស អាចនឹងធ្វើសេចក្តីសំរេចចុងក្រោយលើការលើកឡើងចោទប្រកាន់អំពីឧក្រិដ្ឋកម្មនានា និងអំពីតួនាទីរបស់ជនសង្ស័យទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណ ក៏ដូចជាជនណាមួយផ្សេងទៀតដែលមានភស្តុតាងយ៉ាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាអំពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌប្រឆាំងនឹងពួកគេ។ សហព្រះរាជអាជ្ញាអន្តរជាតិសូមកត់សំគាល់ថា សចស អាចធ្វើការចោទប្រកាន់លើបុគ្គលបន្ថែមថ្មីទាំងនេះ និងមិនជាប់កាតព្វកិច្ចត្រូវតែអនុវត្តតាមការកំណត់អត្តសញ្ញាណជនសង្ស័យនានារបស់សហព្រះរាជអាជ្ញា នោះឡើយ[9] ។ ហេតុដូចនេះ កិច្ចស៊ើបសួរពេញលេញនិងដ៏ត្រឹមត្រូវមួយមិនអាចធ្វើឡើងដោយមិនមានការសំរេចចិត្តថាជនសង្ស័យម្នាក់ឬច្រើននាក់អាចនឹងមិនស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់តុលាការនេះបានឡើយ។ ដើម្បីលើកឡើងជាទឡ្ហីករណ៍ផ្សេងពីនេះ អាចនិងបើកលទ្ធភាពឲ្យករណីរឿងណាមួយអាចត្រូវបានលើកលែងការចោទប្រកាន់ដោយមិនបានបំពេញកិច្ចស៊ើបសួរតាមផ្លូវតុលាការឲ្យបានត្រឹមត្រូវ ដោយផ្អែកលើមូលដ្ឋាននៃការរកឃើញមួយមុនពេលពេកដែលថា ជនសង្ស័យទាំងឡាយដែលត្រូវបាន សហព្រះរាជអាជ្ញា រាយឈ្មោះ គឺមិនស្ថិតនៅក្នុងរង្វង់នៃយុត្តាធិការរបស់តុលាការនេះទេ ។

១១. ដូចដែលបានសំអាងនៅក្នុងសំណើបន្ថែមនានាដូច្នោះដែរ នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ វាជាការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយមានមូលដ្ឋាននៅលើភស្តុតាងដែលអាចមានស្រាប់រហូតមកទល់ពេលនេះ ដែលថា ស៊ូ ម៉េត និង មាស មុត អាចត្រូវបានចាត់ថាជាពួកមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ។ សេចក្តីសម្រេចណាមួយក៏ដោយ ដែលថាជនសង្ស័យទាំងនេះមិនឋិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះនេះ គឺមានលក្ខណៈផ្ទុយទៅនឹងសេចក្តីសន្និដ្ឋាននានាដែល សចស និងអង្គជំនុំជម្រះសាលាដំបូង បានសម្រេចនៅក្នុងសំណុំរឿងលេខ ០០១ ហើយនិងសេចក្តីសន្និដ្ឋាននានាដែល សចស បានសម្រេចនៅក្នុងសំណុំរឿងលេខ ០០២[10] ។

១២. សេចក្តីសន្និដ្ឋាននានាដែលបានដាក់ជូនពីមុន ត្រូវបានធ្វើឡើងដោយឈរលើមូលដ្ឋានបឋមមួយ និងដោយពុំមានប្រយោជន៍ពីការជូនដំណឹងលើបញ្ហានានាដែល សចស កំពុងពិចារណានោះឡើយ ។ នៅក្នុងសំណុំរឿងលេខ ០០២ នៅមុនពេលធ្វើការសម្រេចលើភាពដែលអាចអនុវត្តបាននូវទម្រង់នៃ

---

[9]សេវិធានផ្ទៃក្នុង ៥៥(៤)។

[10] សំណុំរឿងលេខ ០០១, ដីកាដំណោះស្រាយ, ថ្ងៃទី៨ សីហា ២០០៨, D99, ត្រង់ទំព័រទី ៣៣ ។ សាលក្រម, ថ្ងៃទី២៦ កក្កដា ២០១០, E188, ត្រង់ទំព័រទី ៤-៩ ។ សំណុំរឿងលេខ០០២, ដីកាដំណោះស្រាយ, ថ្ងៃទី១៥ កញ្ញា ២០១០, ត្រង់ទំព័រទី ៣៣០ ។

ការទទួលខុសត្រូវស្តីពីសហកម្មឧក្រិដ្ឋកម្មរួម សចស បានអញ្ជើញភាគីនានាឲ្យធ្វើសេចក្តីសន្និដ្ឋាននានាស្តីពីបញ្ហានេះ[11] ។ បើ សចស លើកឡើងបដិសេធសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរចំនួនបី (០៣) ដែលសហព្រះរាជអាជ្ញាអន្តរជាតិកំពុងដាក់ជូននៅពេលនេះ ហើយបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនដោយមានមូលដ្ឋាននៅលើការយល់ឃើញពីបញ្ហាយុត្តាធិការនោះ គេត្រូវតែជូនជូនដំណឹងស្តីពីបញ្ហានានាដែលកំពុងថិតនៅក្រោមការពិចារណាទាំងនេះ និងកាលានុវត្តភាពក្នុងការដាក់សេចក្តីសន្និដ្ឋានពិស្តារតទៅមុខទៀត ដល់សហព្រះរាជអាជ្ញាអន្តរជាតិ ។ ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចដូច្នោះដែរ បញ្ហាយុត្តាធិការគឺមានលក្ខណៈជាសារវន្ត[12] ។

១៣. ត្រឡប់មកនិយាយអំពីស្ថានភាពនៃកិច្ចស៊ើបសួរវិញម្តង ការពិនិត្យទៅលើសំណុំរឿងបង្ហាញឲ្យឃើញថា រយៈពេលសឹងតែ២០ខែ (ចាប់ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១១[13]) ស.ច.ស បានស្តាប់ចម្លើយសាក្សីសរុប២០នាក់ ដែលសាក្សី១៧នាក់ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្ម/ព្រឹត្តិការណ៍ព្រហ្មទណ្ឌចំនួន១០ និងជនសង្ស័យពីរនាក់ ។ ការស្តាប់ចម្លើយទាំងនោះរួមមាន៖

(ក) ការស្តាប់ចម្លើយចំនួនប្រាំ ទាក់ទិននិងមន្ទីរសន្តិសុខ កងពលធំ៨០១ (៨០៨, ៨០៩, ៨១០) ការដ្ឋានកងពលធំ៨០១ (កាឡៃ) និងមន្ទីរសន្តិសុខសម្រាប់ជនស៊ីវិលមួយ (អូរថែង) ដែលហាក់ដូចមិនជាប់ទាក់ទងនឹងកងពលធំ៨០១[14] ឡើយ ។

(ខ) ការស្តាប់ចម្លើយចំនួនដប់ ជាមួយសាក្សីចំនួនប្រាំពីរនាក់ ទាក់ទិននិងកងពលធំ១៦៤ (កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ), ការចាប់កប៉ាល់បរទេស, មន្ទីរសន្តិសុខ វត្តឥន្ទ្រញាណ និងការដ្ឋានវាយថ្មស្ទឹងហាវ ហើយនឹងទីតាំងដែលពាក់ព័ន្ធ[15] ។

(គ) ការធ្វើសម្ភាសន៍ចំនួន បីលើក ទាក់ទងនឹងកងពលធំលេខ៥០២ (កងទ័ពអាកាសនៃកម្ពុជាប្រជាធិបតេយ្យ) ដែលក្នុងនោះរួមមាន ការធ្វើសម្ភាសន៍តែមួយលើកគត់ដែលទាក់ទងនឹងមន្ទីរសន្តិសុខស-២២ នៃកងពលធំលេខ៥០២[16] ។ និង

---

[11] សំណុំរឿងលេខ ០០២, ដីកាសម្រេចលើពាក្យសុំស្តីពីទម្រង់នៃការទទួលខុសត្រូវដែលមានឈ្មោះថា សហឧក្រិដ្ឋកម្មរួម, ថ្ងៃទី១៦ កញ្ញា ២០០៨, D97/III ។

[12] សំណុំរឿងលេខ ០០២, សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១៥ កុម្ភៈ ២០១១, D427/3/15, ត្រង់ទំព័រទី ៣២ ។

[13] សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ, ២៩ មេសា ២០១១, D13 ។

[14] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាន នុំ, ២៤ សីហា ២០១០, D2/5; អ៊ួម កែវ, ២៨ កញ្ញា ២០១០, D2/11, ម៉ៅ ផាត, ២៩ កញ្ញា ២០០១, D2/12, សាយ តាយ, ២៥ កញ្ញា ២០១០, D2/13, មាំង ប៊ួលីន, ២៦ កញ្ញា ២០១០, D2/14 ។

[15] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ូច កុយ, ២៨ កក្កដា ២០១០, D2/4, ញូង ជ្រោង, ២៤ សីហា ២០១០, D2/6, ប៉ែន សារិន, ២៦ សីហា ២០១០, D2/7, សយ ប៊ិន, ៦, ៧ និង ៩ កញ្ញា ២០១០ (D2/8, D2/9, D2/10), ទូច សឿលី, ១០ និង ១១ វិច្ឆិកា ២០១០ (D2/15, D2/16), អ៊ុន សារឿន, ១២ វិច្ឆិកា ២០១០, D2/17 និង សំ ប៊ុនឡេង, ២១ មីនា ២០១១, D8 ។

(ឃ) ការធ្វើសម្ភាសន៍ចំនួនពីរលើកទាក់ទងនឹងតួនាទីរបស់ជនសង្ស័យ ស៊ូ ម៉េត និងមាស មុត នៅក្នុងរចនាសម្ព័ន្ធសិទ្ធិអំណាចនៃកងទ័ពបដិវត្តន៍កម្ពុជា និង បកក[17]។

១៤. ដោយធ្វើការប្រៀបធៀបគ្នា នៅក្នុងសំណុំរឿងលេខ០០២ កសចស បានដឹកនាំធ្វើការសម្ភាសន៍ចំនួនជាង ៨០០លើក ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្ម/ព្រឹត្តការណ៍ឧក្រិដ្ឋកម្មចំនួន២៧កន្លែង និងជនត្រូវចោទចំនួន បួនរូប ។ ចំណែកនៅក្នុងសំនុំរឿងលេខ០០២ មានចម្លើយក្នុងចំនួនដ៏ច្រើនត្រូវបានស្រង់សម្រាប់ទីតាំងនីមួយៗ, នៅក្នុងសំណុំរឿងលេខ ០០៣ ចំនួននៃការធ្វើសម្ភាសន៍សាក្សីជាធម្មតាគឺម្នាក់ឬពីរនាក់សម្រាប់ទីតាំងនីមួយៗ ។ មានការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មចំនួនមួយឃុតគឺបានន័យថាឧក្រិដ្ឋកម្មនានាដែលមានការប្រកាន់ថាបានប្រព្រឹត្តឡើងដោយពួកពលទាហានដែលបញ្ជាដោយកងពលធំលេខ១៦៤ នៅក្នុងទឹកដីនៃប្រទេសវៀតណាម ដែលហាក់ដូចជាមិនមែនជាកម្មវត្ថុនៃការធ្វើសម្ភាសន៍ណាមួយឡើយ។

១៥. សចស បានដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមួយចំនួនដែលទាក់ទងទៅនឹង: (១) មន្ទីរសន្តិសុខ៨០៩ និងការដ្ឋានកាឡៃ[18] (២) គុកអូចែង (Au Cheng) តំបន់៥[19] (៣)មន្ទីរសន្តិសុខស-២២[20] (៤)មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ [21] និង (៥) កន្លែងយកថ្មស្ទឹងហាវ និងការដ្ឋាននានាពាក់ព័ន្ធ[22] ។ ក្នុងការរៀបចំរបាយការណ៍ចំនួនបី លើកទីមួយគឺ កសចស បានពឹងផ្អែកលើព័ត៌មានដែលផ្តល់ដោយសាក្សីម្នាក់សម្រាប់ការដ្ឋានមួយ ។ របាយការណ៍ពីរ លើកទីពីរ ត្រូវបានរៀបចំដោយមានជំនួយពីសាក្សីចំនួនពីរនាក់សម្រាប់ការដ្ឋានមួយ ។

---

[16] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ អ៊ូ លៀង (OU Leang), ចុះសថ្ងៃទី១៣ កក្កដា ឆ្នាំ២០១០, ឯកសារលេខ D2/2, ឈ្មោះ ណុប ហាត *ហៅ* គី ហាត *ហៅ* ណុប ហុន (NOP Hat alias KY Hat alias NOP Hon), ចុះថ្ងៃទី២០ កក្កដា ២០១០, ឯកសារលេខ D2/3 និងឈ្មោះ ស្រេង ធី (Sreng Thi), ចុះថ្ងៃទី១ ធ្នូ ២០១០, ឯកសារ D2/18។

[17] កំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ ឈូក រិន (CHHOUK Rin), ចុះថ្ងៃទី២៤ មីនា ២០១១, ឯកសារលេខ D6 និង ឈ្មោះ កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, ចុះថ្ងៃទី២៧ មេសា ឆ្នាំ២០១១, ឯកសារលេខ D12។

[18] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ចុះថ្ងៃទី៤វិច្ឆិកា ឆ្នាំ២០១០, ឯកសារលេខ D2/19 ។

[19] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ចុះថ្ងៃទី៤វិច្ឆិកា ឆ្នាំ២០១០, ឯកសារលេខ D2/20 ។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងគ្មានការទាក់ទងគ្នាទេ ព្រោះដោយសាររបាយការណ៍នេះពាក់ព័ន្ធនឹងជនស៊ីវិល ហើយដែលទីតាំងនេះមិនជាប់ទាក់ទងជាមួយកងពលធំលេខ៨០១ទេ ។

[20] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ចុះថ្ងៃទី៩ ធ្នូ ឆ្នាំ២០១០, ឯកសារលេខ D2/21 ។

[21] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ចុះថ្ងៃទី២៩ ធ្នូ ឆ្នាំ២០១០, ឯកសារលេខ D2/22 ។

[22] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ចុះថ្ងៃទី៣០ ធ្នូ ឆ្នាំ២០១០, ឯកសារលេខ D2/23 ។

១៦. សកម្មភាពបំពេញកិច្ចស៊ើបសួរបន្ថែមតែមួយគត់ដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានដឹងនោះគឺការផ្ទេរដោយ កសចស នូវឯកសារនៃសំណុំរឿងលេខ០០២ចំនួន ១,២៨៧ ឯកសារ ចូលទៅក្នុងសំណុំរឿងលេខ០០៣[23] នឹងការដាក់បញ្ចូលនៅក្នុងសំណុំរឿងលេខ០០៣នូវបញ្ជីឈ្មោះអ្នកទោស ស-២១ ដែលមកពីកងពលធំលេខ៥០២, ១៦៤, និង៨០១ ចំនួនបីបញ្ជីដែលបានចងក្រងដោយ កសចស[24] ។ ក្នុងពេលដែលមានភស្តុតាងមួយចំនួនដែលត្រូវបានផ្ទេរមកពីសំណុំរឿងលេខ០០២ ឆ្លុះបញ្ចាំងឲ្យឃើញពីព្រឹត្តការណ៍នានាដែលជាន់គ្នាជាមួយនឹងការចោទប្រកាន់ទាំងឡាយដែលមានក្នុងសំណុំរឿងលេខ០០៣ នោះ គឺវាមិនជំនួសឲ្យការស៊ើបសួរនៅក្នុងសំណុំរឿងនេះទាំងស្រុងនោះឡើយ ជាពិសេស ទាក់ទងទៅនឹងការដ្ឋានបន្ថែមថ្មីមួយចំនួន ហើយនិងការទទួលខុសត្រូវរបស់ជនសង្ស័យពីបទឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះ ។

## សេចក្តីរៀបរាប់ដោយត្រួសៗអំពីការរង់ចាំការបំពេញកិច្ចស៊ើបសួរ

១៧. ផលិតផលជាសរុបនៃការស៊ើបអង្កេត គឺបានន័យថា របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស[25], កំណត់ហេតុស្តាប់ចម្លើយសាក្សី, របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង និងសេចក្តីកំណត់ស្តីពីការដាក់បញ្ចូលឯកសារនៅក្នុងសំណុំរឿងលេខ០០៣ ត្រូវបានផ្តល់ដោយសហព្រះរាជអាជ្ញា នៅក្នុងខែមីនា និង ខែមេសា ឆ្នាំ២០១១, ក្នុងពេលមិនយូរប៉ុន្មានមុនពេលចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។ ដីកាចាត់ឱយស៊ើបសួរជំនួសតែមួយគត់ ដែលបានចេញក្នុងករណីរឿងនេះ ត្រូវបានប្រកាសលែងជាការសម្ងាត់ទៀតហើយ កាលពីថ្ងៃទី ១០ ឧសភា២០១១ ហើយដែលហេតុដូចនេះ សហព្រះរាជអាជ្ញាអាចរកបានតែនៅពេលក្រោយពីបិទកិច្ចស៊ើបសួរតែប៉ុណ្ណោះ។ លើសពីនេះ ដោយសាររបាយការណ៍ចំនួនប្រាំបី(៨) ស្តីពីការផ្ទេរឯកសារពីសំណុំរឿងលេខ០០២មិនទាន់បានដាក់នៅឡើយនោះ វិធីសាស្ត្រដែលបានប្រើដោយ កសចស ក្នុងការជ្រើសរើសឯកសារគឺនៅតែមិនទាន់អាចពន្យល់បានជាដដែល[26]។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ មានជំហរថានឹងមិនតាមឃ្លាំមើលដោយប្រសិទ្ធភាព លើកិច្ចស៊ើបសួរឡើយ ហើយ និងមិនដាក់សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនៅមុនពេលការដាក់សេចក្តីជូនដំណឹងស្តីពីការបិទកិច្ចស៊ើបសួរនោះទេ ។

---

[23] សេចក្តីជូនដំណឹងស្តីពីការដាក់បញ្ចូលឯកសារនៅក្នុងសំណុំរឿងលេខ០០៣, ចុះថ្ងៃទី៥ មេសា ២០១១, ឯកសារ D4 (បញ្ជីភ្ជាប់ D4.1)។ សេចក្តីជូនដំណឹងស្តីពីការដាក់បញ្ចូលឯកសារនៅក្នុងសំណុំរឿងលេខ០០៣, ចុះថ្ងៃទី២៥ មេសា ២០១១, ឯកសារ D10 (បញ្ជីភ្ជាប់ជាមួយ D10.1) ។

[24] សេចក្តីជូនដំណឹងស្តីពីការដាក់បញ្ចូលឯកសារនៅក្នុងសំណុំរឿងលេខ០០៣, ចុះថ្ងៃទី២៥ មេសា ២០១១, ឯកសារ D9 (បញ្ជីភ្ជាប់ជាមួយ D9.1, D9.2, D9.3) ។

[25] របាយការណ៍ស្តីពីការអនុវត្តដីការចាត់ឲ្យស៊ើបសួរជំនួស, ១០ កុម្ភៈ ២០១១, D2/1 ។

[26] លទ្ធផលនៃរបាយការណ៍នេះ ត្រូវបានលើកយោងសំដៅអ្វីដែលមាននៅក្នុងរបាយការណ៍ស្តីពីការអនុវត្តដីការចាត់ឲ្យស៊ើបសួរជំនួស *ក្នុងឯកសារដដែលដូចខាងលើ*, ត្រង់ទំព័រទី១ ។

១៨. សូម្បីតែការពិនិត្យបឋមលើសំណុំរឿងក៏បានធ្វើឡើងក្នុងពេលមួយដ៏ខ្លីដែរ នោះវាជាការមួយច្បាស់ណាស់ដែលថាសកម្មភាពបន្ថែមដ៏សំខាន់ទៀតត្រូវតែបានដំណើរការឡើង នៅមុនពេលដែលការស៊ើបសួរអាចត្រូវបានបញ្ចប់ ។ ការណ៍នេះត្រូវបានបញ្ជាក់ដោយរបាយការណ៍នានារបស់អ្នកស៊ើបអង្កេតរបស់ កសចស ។ របាយការណ៍ស្តីពីទីតាំងចំនួនពីរកន្លែងដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតម្នាក់ក្នុងចំណោមអ្នកស៊ើបអង្កេតនានារបស់ កសចស ត្រូវបានបញ្ជាក់គុណវុឌ្ឍិគ្រប់គ្រាន់ថាមានលក្ខណៈ "បឋម" និងបញ្ជាក់លើអង្គហេតុថាការស៊ើបសួរនេះមិនគ្រប់គ្រាន់ទេ ហើយថា គេត្រូវតែធ្វើកិច្ចស៊ើបសួរបន្ថែមទៀត[27] ។ ជាឧទាហរណ៍ នៅក្នុងរបាយការណ៍ទាក់ទងនឹងកន្លែងវាយថ្មនៅស្ទឹងហាវ អ្នកស៊ើបអង្កេតថ្លែងថា៖

> "ទាក់ទងទៅនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង, *ការស៊ើបសួរនៅមិនទាន់ត្រូវបានបំពេញចប់នៅឡើយទេ* ។ មិនមែនគ្រប់តែការស៊ើបសួរដែលអាចធ្វើទៅបាន និងចាំបាច់ទាំងអស់ អាចត្រូវបានធ្វើឡើងនៅពេលដែលគេសរសេររបាយការណ៍នេះ និងនៅមុនពេលដែលដីកាចាត់ឲ្យស៊ើបសួរជំនួសនេះហួសពេល នោះទេ ។ [...] មិនមែនគ្រប់សាក្សីទាំងអស់ រួមមានសាក្សីថ្មីចំនួនបី(០៣)នាក់ដែល កសចស បានកំណត់អត្តសញ្ញាណ អាចត្រូវបានស្តាប់ចម្លើយនៅមុនពេលហួសកាលបរិច្ឆេទនៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួសនេះ នោះទេ ។ ដូច្នេះ របាយការណ៍នេះ មានព័ត៌មានដែលមានកំរិត ពាក់ព័ន្ធទៅនឹងការបង្កើត ការប្រព្រឹត្តទៅ និង សន្តិសុខនៃទីតាំងទាំងនេះ ។ *គេត្រូវ តែធ្វើបច្ចុប្បន្នភាពលើរបាយការណ៍នេះកាលណាមានការស៊ើបសួរបន្ថែមដែលនាំឆ្ពោះទៅរកព័ត៌មានថែមទៀត* [សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត* ]"[28] ។

ក្រោយមក របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស សរសេរថា៖ "សាក្សីមួយចំនួនដែលត្រូវបានអ្នកស៊ើបអង្កេតកំណត់អត្តសញ្ញាណ [ក្នុងអំឡុងពេលស៊ើបសួរ] មិនទាន់ត្រូវបានស្តាប់ចម្លើយនៅឡើយទេ ដោយសារត្រូវផ្តោតធនធានលើការងារពិនិត្យឯកសារ"[29] ។

១៩. របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងពាក់ព័ន្ធនឹងមន្ទីរស-២២ មិនបានបង្ហាញថាមានការស៊ើបសួរណាមួយត្រូវបានធ្វើឡើង ដើម្បីកំណត់អត្តសញ្ញាណពួកអ្នកដែលនៅរស់រានមានជីវិត (ក្រៅពីសាក្សីតែម្នាក់គត់ឈ្មោះ ស្រេង ធី - SRENG Thi), ពួកអ្នកយាមមន្ទីរស-២២ ឬ ពួកកម្មាភិបាលកងពលធំលេខ ៥០២ ដែលអាចផ្តល់នូវព័ត៌មានបន្ថែមបាន នោះទេ ។

២០. ដូចគ្នានេះដែរ ការស៊ើបសួរពីតួនាទីរបស់ជនសង្ស័យចំនួនពីររូបនេះគឺមិនគ្រប់គ្រាន់ទេ ដូចដែលបានបញ្ជាក់យ៉ាងលំអិតនៅក្នុងសំណើរ(សុំឲ្យបំពេញកិច្ចស៊ើបសួរ)បន្ថែមនានា ។ មិនឃើញមានការប៉ុន

[27] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី២៩ ធ្នូ ២០១០, D2/22 ។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី ៣០ ធ្នូ ២០១០, D2/23 ។

[28] របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង, ថ្ងៃទី ៣០ ធ្នូ ២០១០, D2/23, ត្រង់ទំព័រទី៣ ។

[29] របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស, ថ្ងៃទី១០ កុម្ភៈ ២០១១, D2/1, ត្រង់ទំព័រទី១ ។

ប៉ងណាមួយ ដែលទំនងជាត្រូវបានធ្វើឡើងដោយ កសចស ដើម្បីសួរចម្លើយជនសង្ស័យទាំងនេះឡើយ ។ បន្ថែមលើនេះ ជនសង្ស័យទាំងនេះមិនទាន់ត្រូវបានជូនដំណឹងថា ពួកគេគឺជាជនដែលគេត្រូវធ្វើការស៊ើបសួរនោះឡើយ ។ អនុវិធាន ២១.១.ឃ ចែងថា ជនណាដែលត្រូវបាន "សង្ស័យ" មាន "សិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និង មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន" ។ អនុលោមតាមអនុវិធាន ៥៧.១ ជនសង្ស័យត្រូវតែបានប្រាប់ព័ត៌មានអំពីសិទ្ធិទាំងនេះនៅពេលចូលបង្ហាញខ្លួនដំបូងរបស់ពួកគេនៅចំពោះមុខ សចស ។

២១. ទិដ្ឋភាពមួយផ្សេងទៀតនៃការស៊ើបសួរដែលមិនទាន់បានសម្រេចនោះ គឺការតាមដានឲ្យបានគ្រប់គ្រាន់ ដោយមានមូលដ្ឋាននៅលើការវិភាគឯកសារនានាដែលបានផ្ទេរមកពីសំណុំរឿងលេខ ០០២ ។ វាមានការជាក់ច្បាស់ណាស់ដែលថា សចស មិនមានចេតនានឹងធ្វើការស្តាប់ចម្លើយសាក្សីនានានៃសំណុំរឿងលេខ ០០២ នោះទេ (លើកលែងតែ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច និង ឈូក រិន) ដោយមានមូលដ្ឋាននៅលើចម្លើយនានារបស់ពួកគេដែលមានពីមុនមក និងដែលមានការពាក់ព័ន្ធទៅនឹងការលើកឡើងចោទប្រកាន់ជាក់លាក់នានាដែលត្រូវបានធ្វើឡើងនៅក្នុងសំណុំរឿងលេខ ០០៣ ។ ការវិភាគមួយលើចម្លើយនានានៅក្នុងសំណុំរឿងលេខ ០០២ និង ការតាមដានឲ្យបានត្រឹមត្រូវលើការស្តាប់ចម្លើយ គឺមានភាពចាំបាច់យ៉ាងជាក់ច្បាស់ ។ បន្ថែមលើនេះ ឯកសារនានាដែលត្រូវបានផ្ទេរមកពីសំណុំរឿងលេខ ០០២ គួរតែត្រូវបានបង្ហាញដល់សាក្សីទាំងនោះ ដែលពួកគាត់អាចនឹងមិតនៅក្នុងជំហរមួយដែលត្រូវបញ្ជាក់ពីយថាភូតលើឯកសារទាំងនោះ ។

២២. ចុងបញ្ចប់ ការងាកចេញពីការអនុវត្តរបស់ពួកគាត់នៅក្នុងសំណុំរឿងលេខ ០០២ សចស មិនបានធ្វើការប្រកាសជាសាធារណៈអំពីទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍នានាដែលមិតនៅក្រោមការស៊ើបសួរ នៅឡើយទេ ដែលវាបានធ្វើឲ្យមានការពិបាកចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលអាចនឹងមានការដាក់ពាក្យបណ្តឹង ហើយនិងភស្តុតាងដែលនៅមានក្រិតដែលអាចត្រូវបានធ្វើការប្រមូល ។ សហចៅក្រមស៊ើបអង្កេតនឹងបានដឹងថា នៅក្នុងសំណុំរឿងលេខ ០០២ មានភស្តុតាងសំខាន់ៗដែលមានទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មមួយចំនួន ត្រូវបានផ្តល់ឲ្យដោយដើមបណ្តឹងរដ្ឋប្បវេណី ។

## សកម្មភាពជាក់លាក់ដែលស្នើសុំ - ការផ្ទេរ និង ការដាក់ជូននូវឯកសារថ្មីៗ

២៣. ដោយសារទីតាំង(ឧក្រិដ្ឋកម្ម) ហើយការលើកឡើងចោទប្រកាន់ពីអង្គហេតុនានាដែលជាប្រធានបទនៃការស៊ើបសួរនេះ មានចំនួនច្រើនពេក សហព្រះរាជអាជ្ញាអន្តរជាតិនឹងស្នើសុំឲ្យធ្វើការបំពេញកិច្ចស៊ើបសួរលំអិតទាក់ទងទៅនឹងជនសង្ស័យនានា និងទីតាំងឧក្រិដ្ឋកម្មទាំងនោះ នៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម ។ សំណើនេះ ដោះស្រាយជាបឋមពីឯកសារនានាដែលត្រូវដាក់បន្ថែមចូលទៅក្នុងសំណុំរឿងលេខ ០០៣ ។ ជាមូលដ្ឋាននៃការពិនិត្យសំណុំរឿងសារឡើងវិញឲ្យបានក្នុងពេលខ្លីដែលមាននោះ សហព្រះរាជអាជ្ញាអន្តរជាតិបានកំណត់អត្តសញ្ញាណឯកសារបន្ថែមមួយចំនួនក្នុងសំណុំរឿង លេខ០០២ ដែលមានភរនីយភាព និងមានការពាក់ព័ន្ធទៅនឹងកាលើកឡើងចោទ

ប្រកាន់នានានៅក្នុងករណីនេះ ។ គាត់ក៏បានចាត់ការឲ្យមានការពិនិត្យសារថ្មីឡើងវិញផងដែរនូវឯកសារនានាដែលមាននៅការិយាល័យសហព្រះរាជអាជ្ញា ហើយនិងធ្វើការកំណត់អត្តសញ្ញាណឯកសារទាំងឡាយណាដែលមានការពាក់ព័ន្ធបន្ថែមទៀត ដែលមិនបានភ្ជាប់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ។ ប្រភេទខាងក្រោយនេះ រួមមាន ចម្លើយសារភាពនៅមន្ទីរស-២១, បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១, ឯកសារផ្សេងៗដែលមានព័ត៌មានស្តីពីកងពលធំនានានៃកងទ័ពបដិវត្តកម្ពុជា និង កំណត់ហេតុសួរចម្លើយពួកជនសង្ស័យ ។ ចុងបញ្ចប់ មានឯកសារបន្ថែមដែលមានកម្រិតមួយចំនួន ត្រូវបានរកឃើញពីប្រភពសាធារណៈផ្សេងៗក្នុងការត្រៀមរៀបចំធ្វើសំណើសុំទាំងនេះ ។

២៤. អាស្រ័យដោយមូលហេតុនានាដូចដែលបានរៀបរាប់នៅខាងលើនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើសុំឲ្យ៖

(ក) ផ្ទេរឯកសារនានានៅក្នុងសំណុំរឿងលេខ ០០២ ដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធទី១ ចូលទៅក្នុងសំណុំរឿងលេខ ០០៣ ។

(ខ) ដាក់ឯកសារថ្មីនានាដែលមានចុះជាបញ្ជីនៅក្នុងឧបសម្ព័ន្ធទី២ ចូលទៅក្នុងសំណុំរឿងលេខ ០០៣ ។ និង

(គ) ដាក់របាយការណ៍ចំនួនប្រាំបី (០៨) ស្តីពីការពិនិត្យឯកសារឡើងវិញ ដែលបានយោងទៅដល់របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស បញ្ចូលទៅក្នុងសំណុំរឿង ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ | លោក Andrew CAYLEY<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | [signature] |